**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ᠠ

# សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១ : អនុក្រឹត្យនេះមានគោលបំណងកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន ទៅលើខ្លឹមសារ និងរចនាសម្ព័ន្ធ ដែលចែងក្នុងអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

មាត្រា ២ : ត្រូវបានបង្កើតបំពេញបន្ថែមនាយកដ្ឋានចំនួន ៤ ដូចខាងក្រោម ដែលស្ថិតចំណុះក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ :

- នាយកដ្ឋានផែនការ - ហិរញ្ញវត្ថុ
- នាយកដ្ឋានប្រៃសណីយ៍
- នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស
- នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ

មាត្រា ៣ : ត្រូវបានកែសំរួលតួនាទីភារកិច្ច និងឈ្មោះនាយកដ្ឋានរដ្ឋបាលបណ្តុះបណ្តាល និងហិរញ្ញវត្ថុ ទៅជានាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល វិញ ដោយកាត់យកការងារហិរញ្ញវត្ថុ ដែលមានចែងក្នុងចំណុច " ឃ" និង " ខ" នៃមាត្រា ៧ ជំពូក ៥ នៃ អនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ យកមកដាក់បញ្ចូលក្នុងតួនាទីភារកិច្ច របស់នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ នៃអនុក្រឹត្យនេះ វិញ ។

## ជំពូកទី ២

## អំពីរចនាសម្ព័ន្ធគ្រប់គ្រង

មាត្រា ៤ : នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ នាយកដ្ឋានប្រៃសណីយ៍ នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស និង នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ ដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប ( ០១រូប ) និង អនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ ។

4C

មាត្រ ៥ : នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ នាយកដ្ឋានប្រៃសណីយ៍ នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស និង នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ មានការិយាល័យ ចំណុះមួយចំនួនតាមការចាំបាច់ ។ ការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ការិយាល័យចំណុះ បណ្តានាយកដ្ឋាន ដូចមានចែងក្នុងមាត្រា ២ ត្រូវកំណត់ដោយ ប្រកាសរបស់ រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។

## ជំពូកទី ៣

## អំពីភារកិច្ច

មាត្រា ៦ : នាយកដ្ឋានផែនការ-ហិរញ្ញវត្ថុ មានភារកិច្ច ដូចខាងក្រោម :

-សិក្សា និងកសាងគំរោងផែនការអភិវឌ្ឍន៍លើមុខជំនាញប្រៃសណីយ៍ និង ទូរគមនាគមន៍ រយៈពេលមធ្យម និង រយៈពេលវែង

-កសាងគំរោងផែនការចំណូល-ចំណាយហិរញ្ញវត្ថុ

-គ្រប់គ្រងការងារប្រមូលចំណូលអាជីវកម្ម-សេវាកម្ម លើមុខជំនាញប្រៃសណីយ៍ និង ទូរគមនាគមន៍

-គ្រប់គ្រងបេឡាសាច់ប្រាក់ជារៀល និងរូបិយប័ណ្ណតាមច្បាប់ហិរញ្ញវត្ថុជាធរមាន

-គ្រប់គ្រងសំភារៈ និងបរិក្ខារបស់ក្រសួង

-គ្រប់គ្រងការងារលទ្ធកម្មសាធារណៈ

-គ្រប់គ្រងការងារវិក័យប័ត្រ

-គ្រប់គ្រងការងារសំណង់ វិស្វកម្ម

-អនុវត្តន៍ភារកិច្ចផ្សេង ៗ ទៀត ដែលក្រសួងប្រគល់អោយ ។

មាត្រា ៧ : នាយកដ្ឋានប្រៃសណីយ៍ មានភារកិច្ចដូចខាងក្រោម :

-គ្រប់គ្រងនិងធ្វើអាជីវកម្ម លើបណ្តាសេវាប្រៃសណីយ៍ ដែលបានកំណត់តាមច្បាប់ស្តីពីវិស័យប្រៃសណីយ៍

-ទទួលសិទ្ធក្នុងការបោះពុម្ពតែមប្រៃសណីយ៍ តែមប្រើពិន័យ និងរាល់លិខិតស្នាមសំរាប់វិស័យប្រៃសណីយ៍

-គ្រប់គ្រង និង រៀបចំឯកសារផែនការអភិវឌ្ឍន៍ សំរាប់រយៈពេលមធ្យម និង រយៈពេលវែង នៃវិស័យ ប្រៃសណីយ៍ទូទាំងប្រទេស

-គ្រប់គ្រងចំណូលអាជីវកម្ម-សេវាកម្មប្រៃសណីយ៍គ្រប់ប្រភេទ

-កសាងគំរោងផែនការចំណូល-ចំណាយថវិកា តាមតំណាក់កាលនិមួយ ៗ

-កសាងគំរោងផែនការសហប្រតិបត្តិការជាមួយបរទេស ស្តីពីការទំនាក់ទំនងអាជីវកម្ម-សេវាកម្មប្រៃសណីយ៍

-អនុវត្តន៍ភារកិច្ចផ្សេង ៗ ទៀត ដែលក្រសួងប្រគល់អោយ ។

មាត្រា ៨ : នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ មានភារកិច្ចដូចខាងក្រោម :

-គ្រប់គ្រងបណ្តាញទូរគមនាគមន៍ និងធ្វើសេវាកម្មមាត់ច្រកអន្តរជាតិ

-ធ្វើគំរោងអភិវឌ្ឍន៍បណ្តាញទូរគមនាគមន៍អន្តរជាតិ

-គ្រប់គ្រងការបញ្ជូន និងទទួលរូបភាពទៅអន្តរជាតិ

-គ្រប់គ្រងការជួលជាវបរិបថអន្តរជាតិ

-គ្រប់គ្រងប្រព័ន្ធវិទ្យុឆ្នេរសមុទ្រ តាមដងទន្លេ

-សំរបសំរួលបណ្តាញទូរគមនាគមន៍ ពីមាត់ច្រកអន្តរជាតិ ទៅប្រទេសជាដៃគូទាំងអស់លើពិភពលោក

-អនុវត្តន៍ភារកិច្ចផ្សេង ៗ ទៀត ដែលក្រសួងប្រគល់អោយ ។

មាត្រា ៩ : នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស មានភារកិច្ចដូចខាងក្រោម :

-គ្រប់គ្រងមជ្ឈមណ្ឌលទូរស័ព្ទ របស់ក្រសួងដែលមានទាំងអស់ និងមជ្ឈមណ្ឌលទូរស័ព្ទ សាធារណៈ និង បណ្តូសព្ទ

-សហការ ការងារបច្ចេកទេសជាមួយប្រតិបត្តិករទូរស័ព្ទជាដៃគូ ជាមួយក្រសួងបណ្តាទូរគមនាគមន៍ខេត្ត-ក្រុង និងនាយកដ្ឋានចំណុះក្រសួង

-កសាងគំរោងផែនការអភិវឌ្ឍន៍បណ្តាញនៅទីក្រុង និងជនបទតាមផែនការមេ

-គ្រប់គ្រង និងជួសជុលបណ្តាញទូរស័ព្ទ បណ្តាញបញ្ជូនស៊ីញ៉ាល់តាមកាប្លិ៍អុបទិក

-កសាងគំរោងចំណូលចំណាយ នៃការធ្វើអាជីវកម្ម លើវិស័យទូរគមនាគមន៍

-សហការសិក្សារៀបចំគំរោងអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ជាមួយប្រទេសផ្តល់ជំនួយ

-អនុវត្តន៍ភារកិច្ចផ្សេង ៗ ទៀត ដែលក្រសួងប្រគល់អោយ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

មាត្រា ១០ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តន៍តាមខ្លឹមសារ នៃអនុក្រឹត្យនេះ តាមភារកិច្ចរៀង ៗ ខ្លួន ។

មាត្រា ១១ : អនុក្រឹត្យនេះ មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខា រហូតដល់គ្រឹស្ថានសាធារណៈ លើវិស័យទូរគមនាគមន៍ កម្ពុជា និង ប្រៃសណីយ៍ កម្ពុជា ត្រូវបានបង្កើតឡើង ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្ដីជំរាបជូន សម្ដេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

សូរ ឃុន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង

" ដើម្បីជូនជ្រាប "

-ដូចមាត្រា ១០ " ដើម្បីអនុវត្តន៍ "

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

## របនាសម្ព័ន្ធរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

